# អភិបូជាបិទកម្មវិធីបូជនីយ៍ចរ
# ធ្វើនៅកសិដ្ឋានឋានសួគ៌ ភ្នំវល្លិ៍
# ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២២
# "យើងជាសាក្សីរបស់ព្រះយេស៊ូ"

**អត្ថបទទី១៖ អេសាយ ៦,១-២ក.៣-៨**

តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់យើង? អស ៦,៨

**អត្ថបទទី២៖ កូរិនថូសទី១ ១៥,១-១១**

បងប្អូននឹងទទួលការសង្គ្រោះ តាមរយៈដំណឹងល្អ។ ១ករ ១៥,២

**ដំណឹងល្អ៖ លូកា ៥,១-១១**

គេបោះបង់របស់របរទាំងអស់ចោល រួចនាំគ្នាដើរតាមព្រះយេស៊ូទៅ។ លក ៥,១១

បងប្អូនជាទីស្រឡាញ់

"**សូមឱ្យនាំគ្នីគ្នាច្រៀងរាំ តម្កើងកិច្ចការ ថាព្រះអម្ចាស់រុងរឿងអស្ចារ្យ ឧត្តមថ្លៃថ្លាបំផុតគ្មានពីរ**" ពីយប់មិញយើងបានរាំ យើងបានច្រៀង ប៉ុន្តែមិនមែនតែរាំច្រៀងដើម្បីសប្បាយៗគ្នាយើង រាំច្រៀងដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ នៅពេលយើងដើរ យើងនឿយហត់ ក្តៅផងសប្បាយផង ឈឺជើងផង ជាប់សាច់ដុំផង... យើងដឹងថាយើងបានដើរនៅក្នុងការតស៊ូ យើងបានបែកញើសនៅក្នុងការតស៊ូ។ ប៉ុន្តែ យើងក៏មានពេលដើម្បីអធិដ្ឋាន ដើម្បីសូត្រផ្តាំ ដើម្បីសម្លឹងមើលទេសភាពយ៉ាងពិសេស ដែលមាននៅក្នុងតំបន់ភ្នំវល្លិ៍នេះ ដែលជាស្នាដៃរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ យប់មិញនៅពេលយើងសប្បាយរួមគ្នា ជាពេលវេលាមួយដើម្បីបង្ហាញអំណរសប្បាយដែលយើងមាន។ ដោយសារ ព្រះជាម្ចាស់បានបង្កើតយើង ព្រះជាម្ចាស់ធ្វើដំណើរជាមួយយើង ព្រះជាម្ចាស់ស្រឡាញ់យើង។

បងប្អូនដែលជាយុវជនយុវនារី ដែលបានចូលជាមួយយើងរយៈពេលពីរថ្ងៃ ក៏ដូចជាបងប្អូនយុវជនយុវនារីនៅក្នុងភូមិភាគភ្នំពេញទាំងមូល នៅក្នុងឆ្នាំថ្មីនេះដែលភ្ជាប់ជាមួយឆ្នាំសិក្សាថ្មី ដែល

ភ្ជាប់នៅក្នុងឆ្នាំសកម្មភាពនៅក្នុងព្រះសហគមន៍ថ្មី។ ដោយសារ ពេលវេលាប្រែប្រួលអស់ហើយព្រោះតែកូវីដ-១៩ ជាកម្លាំងដែលយើងទទួលរួមជាមួយគ្នានៅក្នុងព្រះយេស៊ូគ្រីស្ត។ ពីម្សិលមិញយើងបានឃើញព្រះជាម្ចាស់បានបង្កើតយើង ព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់មានគម្រោងការតែមួយគឺណែនាំឱ្យយើងទាំងអស់គ្នា ពោរពេញដោយសុភមង្គល។ ថ្ងៃនេះ យើងបានឃើញព្រះយេស៊ូកំពុងត្រាស់ហៅសាវ័ក ពីសម័យដើមព្រះយេស៊ូនៅក្នុងសមុទ្រទីបេរីយ៉ា ក្នុងប្រទេសអ៊ីស្រាអែល។ ប៉ុន្តែ តាមពិតយើងដឹងថាពីម្សិលមិញយើងឃើញនៅក្នុងវិហារយើង មានកញ្ចក់មួយផ្ទាំងដែលមានរូបព្រះយេស៊ូ ដែលកំពុងត្រាស់ហៅសាវ័កនៅសមុទ្រកែបនិងភ្នំបូកគោ។ ដោយសារ អ្វីដែលកើតឡើង២០០០ឆ្នាំមុននៅស្រុកកាលីឡេ គឺកើតសព្វថ្ងៃនៅក្នុងប្រទេសកម្ពុជាដែរ ព្រះយេស៊ូត្រាស់ហៅយើងសព្វថ្ងៃ ព្រះយេស៊ូចង់ឱ្យយើងទាំងអស់គ្នាធ្វើដំណើររួមជាមួយព្រះអង្គ។ សំណួរដែលយើងត្រូវការទុកនៅក្នុងដួងចិត្តរបស់យើងគឺ **តើយើងសុខចិត្តលះបង់ចោលអ្វីៗទាំងអស់ ដើម្បីដើរតាមព្រះយេស៊ូដែរឬទេ?**

ប្រសិនបើ យើងសុខចិត្តយើងថាទាំងអស់គ្នាយើងទៅជាបងប្រុសបងស្រី ជាបូជាចារ្យ ប៉ុន្តែយើងជាគ្រីស្តបរិស័ទធម្មតា យើងក៏ត្រូវតែធ្វើជាសាក្សីអំពីជំនឿដែលយើងបានទទួល សាក្សីអំពីកម្លាំងដែលយើងទទួលពីព្រះជាម្ចាស់ សាក្សីអំពីសេចក្តីស្រឡាញ់។ យើងបានចាប់អារម្មណ៍អំពីអត្ថបទទី២ លោកប៉ូលគាត់ផ្តល់សក្ខីភាពអំពីអ្វីដែលគាត់បានស្តាប់ ពីសាក្សីបន្ទាល់ដែលបានឃើញព្រះយេស៊ូផ្ទាល់។ ព្រះយេស៊ូបានសោយទិវង្គត ព្រះយេស៊ូបានចូលនៅក្នុងផ្នូរ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី។ លោកប៉ូលបានស្តាប់ពីគេ ដោយសារលោកប៉ូលអត់ដែលជួបជាមួយព្រះយេស៊ូផ្ទាល់ដូចក្រុមគ្រីស្តទូតពីដើម។ លោកប៉ូលស្តាប់ពីគេ មានខ្លះគេស្លាប់ហើយប៉ុន្តែគេបន្តផ្តល់សក្ខីភាពតៗគ្នា សព្វថ្ងៃដល់យើងនៅប្រទេសកម្ពុជា ដល់យើងជាយុវជនយុវនារីនៅក្នុងភូមិភាគភ្នំពេញ។ ផ្តល់សក្ខីភាពតៗគ្នា ជាង២០០០ឆ្នាំដែលក្រុមគ្រីស្តទូតបានជួបជាមួយព្រះយេស៊ូផ្ទាល់ ដែលបានស្តាប់ព្រះយេស៊ូផ្ទាល់ ដែលមើលឃើញព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាងផ្ទាល់ ដែលបានឃើញព្រះយេស៊ូបង្ហាញខ្លួននៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញផ្ទាល់។ ក្រោយមក គេចាប់ផ្តើមផ្តល់សក្ខីភាពតៗគ្នាដោយស្តាប់ ដូចយើងកំពុងស្តាប់ដែរ យើងស្តាប់លោកតាលោកយាយដែលផ្តល់សក្ខីភាព អំពីជីវិតមុនសម័យប៉ុល ពត អំពីជីវិតនៅក្នុងសម័យប៉ុល ពត អំពីជីវិតនៅក្នុងសម័យក្រោយប៉ុល ពត យើងស្តាប់ឪពុកម្តាយដែលផ្តល់សក្ខីភាព។ ដូច្នេះសម្រាប់យើងថ្ងៃនេះទោះបីយើងនៅក្មេងក៏ដោយ យើងទទួលតួនាទីមួយយ៉ាងពិសេស គឺយើងជាសាក្សីដែលផ្តល់សក្ខីភាពអំពីព្រះយេស៊ូ ដែលគង់នៅជាមួយយើងសព្វថ្ងៃ។

បទពិសោធន៍ដែលយើងមានប៉ុន្មានថ្ងៃកន្លងមក គឺជាបទពិសោធន៍ដែលណែនាំឱ្យយើងមានអំណរសប្បាយរួមគ្នា។ ប៉ុន្តែ អំណរសប្បាយនេះមិនមែនជាអំណរសប្បាយដែលមកពីលោកីយ ជាអំណរសប្បាយដែលមានដោយសារយើងជួបជុំគ្នាដោយនាមព្រះជាម្ចាស់។ ពេលយើងចាប់ផ្តើមប្រមូលយុវជនយុវនារីតាមកន្លែងនីមួយៗ ជារបៀបដែលយើងត្រាស់ហៅដែរ ជារបៀបព្រះយេស៊ូដែលកំពុងធ្វើការនៅក្នុងយើងដែរ។ តាមរយៈ ការិយាល័យយុវជន តាមរយៈលោកឪពុកដែលបានប្រមូល និងយើងបានឆ្លើយតបដូចក្រុមគ្រីស្តទូតពីដើម។ យើងបានទុកចោលតួនាទីការងារ ការសិក្សារបស់យើង ពីរបីថ្ងៃ ដើម្បីជួបជុំគ្នានៅកំពត ដើម្បីដើររួមគ្នា ដើម្បីស្តាប់ព្រះបន្ទូល ដើម្បីបង្កើតទំនាក់ទំនងជាមួយមិត្តសម្លាញ់ថ្មី ដើម្បីមើលឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ដែលបានបង្កើតពិភពលោកទាំងមូល។ យើងបានលះបង់ចោល សុខចិត្តដើរជាមួយព្រះយេស៊ូនៅក្នុងរយៈពេលបីថ្ងៃនេះ។ នៅពេលយើងត្រឡប់ទៅវិញ នៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់ ឱ្យយើងបន្តធ្វើជាសាក្សីដែលយើងទទួលសក្ខីភាពយើង ទទួលតួនាទីមួយសំខាន់ គឺយើងផ្តល់សក្ខីភាពដល់យុវជនតៗ។

មានប៉ុន្មានកន្លែងដែលយុវជនចង់មកច្រើន ដូច្នេះយើងជាតំណាងដែលព្រះជាម្ចាស់បានជ្រើសរើស ពេលយើងទៅវិញឱ្យយើងគិតជាមួយលោកឪពុក ជាមួយបងប្រុសបងស្រី **តើយើងធ្វើដូចម្តេចដើម្បីប្រមូលយុវជនយុវនារីយើងតៗ?** កុំឱ្យកម្លាំងដែលយើងបានទទួលនៅក្នុងរយៈពេលពីរថ្ងៃ ជាកម្លាំងណែនាំឱ្យយើងសប្បាយមែន ណែនាំឱ្យយើងមានសេចក្តីសង្ឃឹមមែន ប៉ុន្តែក្រោយមកបន្តិចម្តងៗវាចុះទៅៗ។ ផ្ទុយទៅវិញ ឱ្យវារីកចម្រើនទៅៗដើម្បីណែនាំឱ្យកន្លែងនីមួយៗ ដឹងថានៅក្នុងភូមិភាគយើង យើងមានព្រះវិហារ៥០កន្លែងដែលមានយុវជនយុវនារី ដែលចង់ស្តាប់ដំណឹងល្អ ដូចពីដើមលោកប៉ូលណែនាំឱ្យដំណឹងល្អទៅគ្រប់ទីកន្លែង។ តាមពិត យើងទាំងអស់គ្នាយើងជាគ្រីស្តទូតតូចមួយ ប៉ុន្តែមិនមែនតូចដោយសារយើងអត់មានអំណាច អត់មានឋានៈ យើងជាគ្រីស្តទូតដ៏តូចមួយពោរពេញដោយអត្ថន័យ។ ដែលណែនាំឱ្យព្រះបន្ទូលទៅមុខបាន ដែលណែនាំឱ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់គ្រប់ទីកន្លែង។ អាទិត្យមុន ខ្ញុំបានស្តាប់ក្រុមជំទង់ដែលថា យើងខិតខំសួរសុខទុក្ខអ្នកជំងឺ យើងខិតខំបម្រើអសានៈ យើងខិតខំច្រៀង យើងខិតខំសម្អាតបរិវេណព្រះវិហារ គេបានផ្តល់សក្ខីភាពរបស់គេ។ យើងជាយុវជនយុវនារីនៅទីនេះ **តើយើងបានធ្វើអ្វីខ្លះ ដើម្បីឱ្យសេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់ អាចទៅជាសេចក្តីស្រឡាញ់សម្រាប់បងប្អូនឯទៀតៗ?**

ព្រះជាម្ចាស់បានត្រាស់ហៅយើងដូចក្រុមគ្រីស្គទូតពីដើម ព្រះជាម្ចាស់ណែនាំឱ្យយើងទៅជាសាក្សីនៃសេចក្តីស្រឡាញ់។ ហេតុនេះហើយ ពេលយើងទៅវិញឱ្យយើងប្រមូលយុវជនយុវនារីរបស់យើង ដើម្បីបន្តរស់នៅក្នុងអំណរសប្បាយដែលយើងបានទទួលពីព្រះជាម្ចាស់ ណែនាំឱ្យជីវិតរបស់យើងទៅជាមានសេចក្តីសុខ និងមានសុខដុមរមនា។ យើងជានិស្សិត យើងជាសិស្សសាលា យើងជាអ្នកធ្វើការ នេះជាជីវិតធម្មតារបស់យើង ប៉ុន្តែជីវិតធម្មតារបស់យើងទទួលពន្លឺពីព្រះជាម្ចាស់ផ្ទាល់ ពន្លឺពីសេចក្តីស្រឡាញ់ដែលយើងទទួលពីព្រះជាម្ចាស់។ ហេតុនេះហើយ យើងបាននឹកឃើញក្នុងជីវិតរបស់យើង យើងមានជីវិតធម្មតា ប៉ុន្តែយើងមានសេចក្តីស្រឡាញ់តាមរយៈវិន័យរបស់លោកម៉ូសេទាំង១០ប្រការ។ ប៉ុន្តែ តាមរយៈវិន័យរបស់ព្រះយេស៊ូ "សូ**មស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**"។ ព្រះយេស៊ូបានស្រឡាញ់យើងរហូតដល់បូជាជីវិតនៅលើឈើឆ្កាង ប៉ុន្តែព្រះយេស៊ូណែនាំឱ្យយើងទាំងអស់ទៅជាសាក្សីនៃសេចក្តីស្រឡាញ់នេះពីមួយថ្ងៃទៅមួយថ្ងៃ។

ដូច្នេះ ខ្ញុំសូមអញ្ជើញឱ្យបងប្អូនទាំងអស់គ្នា ខិតខំអស់ពីសមត្ថភាព យើងបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូថ្ងៃនេះ "**កុំខ្លាចអី ខ្ញុំណែនាំឱ្យអ្នកធ្វើជាអ្នកនេសាទមនុស្សវិញ**"។ យើងទាំងអស់គ្នាយើងជាអ្នកនេសាទ មិនមែននេសាទត្រី មិនមែននេសាទមនុស្សដោយចាប់គេឱ្យគេបាត់បង់សេរីភាព។ ផ្ទុយទៅវិញ នេសាទមនុស្សដោយផ្តល់សក្ខីភាព ដើម្បីឱ្យមនុស្សមួយចំនួនយ៉ាងធំ អាចស្តាប់ដំណឹងល្អដែលណែនាំឱ្យយើងមានកម្លាំងថ្មី ដើម្បីរស់នៅជាមនុស្សយ៉ាងត្រឹមត្រូវនៅក្នុងសង្គមបច្ចុប្បន្ននេះ។

ខ្ញុំអធិដ្ឋានទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់យុវជនយុវនារីដែលនៅទីនេះ ដែលជាគ្រីស្តទូតដែលជាកីឡាកររបស់ព្រះជាម្ចាស់ ដែលជាទាហានរបស់ព្រះជាម្ចាស់ ដែលតស៊ូជានិច្ច ដែលដើរជានិច្ច ទៅមុនជានិច្ច។ ណែនាំទៅយុវជនថែមទៀត អាចទទួលដំណឹងល្អអំពីព្រះយេស៊ូគង់នៅអំពីព្រះជាម្ចាស់ដែលបានបង្កើតយើង អំពីព្រះជាម្ចាស់ដែលបានប្រទានពិភពលោកទាំងមូលដើម្បីឱ្យយើងគ្រប់គ្រង ដើម្បីឱ្យយើងរស់នៅជាគ្រួសារតែមួយដែលពោរពេញដោយកម្លាំងដែលមកពីព្រះជាម្ចាស់ផ្ទាល់។ សូមព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយុវជនយុវនារីទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ដើម្បីឱ្យឆ្នាំ២០២២នេះ ទៅជាឆ្នាំដែលយើងដើររួមជាមួយគ្នា ដើម្បីប្រកាសដំណឹងល្អ។ ដែលយើងទាំងអស់គ្នា ចូលរួមយ៉ាងសកម្មបំផុត ដើម្បីឱ្យព្រះសហាគមន៍យើងរីកចម្រើន និងឱ្យសង្គមយើងពោរពេញដោយសេចក្តីសង្ឃឹមថែមទៀត។ រីកចម្រើនលូតលាស់ដើម្បីទៅជាសង្គមដែលទទួលសេចក្តីស្រឡាញ់ ទទួលយុត្តិធម៌ពីគ្នាទៅវិញទៅមក ដោយសារ

យើងដឹងថា យើងជាសាក្សីរបស់ព្រះយេស៊ូ ដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូដែលគង់នៅសព្វថ្ងៃ ព្រះយេស៊ូដែលជាធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលយើងមើលឃើញយ៉ាងជាក់ស្ដែង។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ៉ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/XPCXqMgwV4o